ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខៈ.....✓........................

# សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
## និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ** - ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារេត អគ្គលេខាធិការរង គ.ជ.ប.ជ និងជាប្រធានក្រុមការងារទទួលបន្ទុកកំណត់ហេតុ របាយការណ៍

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ៖** ស្តីពី ការប្រារព្ធទិវាជាតិ ១២ធ្នូ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ ។

ថ្ងៃអង្គារ ១៥ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១៤;៣០ នាទីរសៀល នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ មានប្រារព្ធទិវាជាតិ ១២ធ្នូ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលោកជំទាវ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

### I. សមាសភាពចូលរួម

- **សម្តេចសង្ឃរាជទាំងពីរគណៈ**
- **ឯកឧត្តម លោកជំទាវ** ប្រធាន អនុប្រធានគណៈកម្មការទាំង១០ នៃព្រឹទ្ធសភា
- **ឯកឧត្តម លោកជំទាវ** ប្រធាន អនុប្រធានគណៈកម្មការទាំង១០ នៃរដ្ឋសភា
- **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន គ.ជ.ប.ជ និងជាប្រធានក្រុមការងារទេសន្តប្រវេសន៍
- **ឯកឧត្តម ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន គ.ជ.ប.ជ និងជាប្រធានក្រុមការងារការពារជនរងគ្រោះ
- **ឯកឧត្តម នាយឧត្តមសេនីយ៍ ស ថេត** អគ្គស្នងការនគរបាលជាតិ អនុប្រធាន គ.ជ.ប.ជ និងជាប្រធានក្រុមការងារអនុវត្តច្បាប់
- **ឯកឧត្តម លោកជំទាវ** តំណាងស្ថាប័នតុលាការ
- **ឯកឧត្តម លោកជំទាវ** រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង លោក លោកស្រី ប្រធាន អនុប្រធាននាយកដ្ឋាន តំណាងក្រសួង ស្ថាប័ន
- **ឯកឧត្តម លោកជំទាវ** អភិបាល អភិបាលរងទទួលផែន រាជធានី/ខេត្ត
- ស្នងការ ស្នងការរងទទួលផែន រាជធានី/ខេត្ត

- កងកម្លាំងនគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស កងកម្លាំងការពារព្រំដែនគោក និងព្រំដែនទឹក នៃកងយោធពលខេមរភូមិន្ទ
- មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ គ្រឹស្ថានឧត្តមសិក្សា កាយរិទ្ធិកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា យុវជនកាកបាទក្រហមកម្ពុជា
- តំណាងសាសនាធំៗទាំង៣ ក្នុងព្រះរាជាណាចក្រកម្ពុជា
- ស្ថានទូត ស្ថានតំណាងប្រចាំព្រះរាជណាចក្រកម្ពុជា
- ប្រធាន និងតំណាងអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងតំណាងស្ថាប័នពាក់ព័ន្ធ

**សរុបចំនួន៖ ៣,១២៥ អង្គ/នាក់**

## II.មតិស្វាគមន៍ និងរបាយការណ៍សង្ខេប

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានមតិស្វាគមន៍ និងរបាយការណ៍សង្ខេប ស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជូន **ឯកឧត្តម អភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ និង លោកជំទាវ** ព្រមទាំងគណៈអធិបតីក៏ដូចជាអង្គពិធីទាំងមូល ។ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ មានប្រសាសន៍ថា៖ ថ្ងៃនេះ ១២ធ្នូ ឆ្នាំ២០២៣ គឺជាថ្ងៃ ប្រារព្ធទិវាជាតិ ១២ ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខួបលើកទី១៧ បើគិតពីការដាក់ចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ឆ្នាំ២០០៧ និងជាការប្រារព្ធពិធី លើកទី៩ គិតចាប់ពីថ្ងៃទី១២ធ្នូ ឆ្នាំ២០១៥ ដែលរៀបចំដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ការប្រារព្ធពិធីនេះ គឺជាយុទ្ធនាការដ៏ធំមួយក្នុងគោលបំណង ផ្សព្វផ្សាយការយល់ដឹង ឲ្យកាន់តែទូលំទូលាយ អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់ទម្រង់ ។

**លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍** មានប្រសាសន៍គោរពទូលថ្វាយ ប្រគេនសម្តេចព្រះសង្ឃរាជ និងគោរពជម្រាបជូន **ឯកឧត្តម អភិសន្តិបណ្ឌិត** និង **លោកជំទាវ** ព្រមទាំងអង្គពិធីទាំងមូល អំពីសកម្មភាព និងលទ្ធផលនៃសកម្មភាព និងលទ្ធផល នៃការអនុវត្តយុទ្ធសាស្ត្រ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆ្នាំ២០២៣ កន្លងមក ដែលមានដូចខាងក្រោម៖

បញ្ហាឥទ្ធិពល និងផលប៉ះពាល់ នៃវិបត្តិសេដ្ឋកិច្ច សង្គម នយោបាយ ជាសាកល ដែលបណ្តាលមកពីវដ្តនៃធម្មជាតិ មានជាអាទិ៍ ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី បម្រែបម្រួលអាកាសធាតុ ការកើនឡើងនូវខ្យល់កខ្វក់ ការឡើងកំដៅ ភ្លើងឆេះព្រៃ...។ល។ និងផលប៉ះពាល់ពីសង្គ្រាមប្រដាប់អាវុធ ការរាតត្បាតនៃជំងឺឆ្លងជាពិសេស កូវីដ-១៩ និងមេរោគបំប្លែងថ្មីជាដើម បានបង្កឲ្យមានគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ដល់ជីវិតមនុស្សលើផែនដី គ្រប់វ័យ គ្រប់ភេទ គ្រប់ជាតិសាសន៍ គ្រប់ស្ថានភាព និងគ្រប់ទីកន្លែង ។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរឹត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយ បង្កើតនូវបទល្មើសថ្មីៗ ព្រមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស ។

**លោកជំទាវ** មានប្រសាសន៍បន្តថា គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងមន្ទីរ អង្គភាព ក្រោមឱវាទ រាជធានី-ខេត្ត ជាសមាជិក នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ នៅគ្រប់កម្រិត និងមានការចូលរួមគាំទ្រ សហការដោយអង្គការសហប្រជាជាតិ អង្គការដៃគូ ជាតិ និងអន្តរជាតិ ពាក់ព័ន្ធបានបន្តធ្វើសកម្មភាពប្រតិបត្តិការតាមយុទ្ធសាស្ត្រទាំងបួន ដែលបានកំណត់។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គឺជាយន្តការសម្របសម្រួល ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ដោយបានជួបប្រជុំពិភាក្សាជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធជាប្រចាំ រាល់ការរៀបចំគោលការណ៍ ផែនការ រយៈពេលខ្លី មធ្យម វែង ការរៀបចំបទដ្ឋាននីតិវិធីនានា ។ កិច្ចប្រជុំពិគ្រោះយោបល់រវាង ក្រសួង ស្ថាប័ន ជំនាញពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដើម្បីធ្វើការវាយតម្លៃផែនការយុទ្ធសាស្ត្រ ប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ និងរៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំបន្ត ២០២៤-២០២៨ ។ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ បាន និងកំពុងសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យកែសម្រួលគោលការណ៍ណែនាំ ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងប្រព័ន្ធបញ្ជូនថ្នាក់ជាតិ សម្រាប់អនុវត្តទូទាំងប្រទេស ។ គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលដល់ក្រុមមន្ត្រីជួរមុខនៅគ្រប់ខេត្ត និងរាជធានី ដើម្បីអនុវត្តឲ្យបានព្រមៗគ្នា ។

បច្ចុប្បន្ននេះ ក្រសួង ស្ថាប័នពាក់ព័ន្ធជាសមាជិក នៃគណៈកម្មាធិការជាតិ និងនៅថ្នាក់ក្រោមជាតិ បានរួមគ្នាដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងមហាអនុតំបន់មេគង្គ តាមរយៈយន្តការទ្វេភាគី ពហុភាគី នៃក្រុមការងារ COMMIT - ក្នុងតំបន់អាស៊ាន តាមរយៈ ក្រុមការងារ SOMTC និងគម្រោងអាស៊ាន អូស្ត្រាលី - ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក តាមរយៈ យន្តការ Bali Process - និង នៅថ្នាក់ពិភពលោកតាមរយៈបណ្តាញទេសន្តរប្រវេសន៍ អន្តរជាតិ និងអង្គការសហប្រជាជាតិ ដែលកម្ពុជា ក៏ជាសមាជិកផងដែរ ។

**លោកជំទាវ** មានប្រសាសន៍ប្រគេន និងគោរពជម្រាបជូន បន្តថា ដោយឡែក អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក៏ដូចជាបណ្តាក្រសួង អង្គភាព ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានរួមសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ មានទាំងអង្គការសង្គមស៊ីវិលជាដៃគូជាតិ អន្តរជាតិ វិស័យឯកជន ទាំងការពិគ្រោះពិភាក្សា ការចូលរួមគាំទ្រសកម្មភាពនានា ទាំងកម្លាំងកាយចិត្ត ធនធាន បច្ចេកទេស ទៅគ្រប់សកម្មភាពក្នុងយុទ្ធសាស្ត្រទាំងបួន មានជាអាទិ៍ អង្គការ IOM, UNICEF, UNFPA, UNWomen, ILO, WHO, ERIKS JALPEN, ASEAN-ACT, CHAB DAI, CARITAS SWISS, CARITAS CAMBODIA, PLAN, IJM, UNDP, AIM, RATANAK, USAID, WINROCK International, APLE, HAGAR, SAMARITAN's PURSE, CPU, LSCW, CWCC, EU, Hope of Justice, ...និងអង្គការមួយចំនួនទៀត។ **ចំណែកឯក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានដឹកនាំក្រុមការងារបច្ចេកទេសធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយ ភាគីថៃ គណៈប្រតិភូប្រទេសឡាវ វៀតណាម និងក្រុមការងារថ្នាក់តំបន់ ពាក់ព័ន្ធនឹងសុវត្ថិភាពការងារ ការអភិវឌ្ឍជំនាញ ការដោះស្រាយវិវាទ រវាងនិយោជក និងនិយោជិតជាដើម ។

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មានប្រសាសន៍លើកឡើងបន្តថា កន្លងមក ប្រជាជនកម្ពុជាជាច្រើន បានរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ក្នុងអំឡុងពេល នៃការធ្វើទេសន្តរប្រវេសន៍ស្វែងរកការងារនៅ

ក្រៅប្រទេស រាប់រយនាក់ក្នុងមួយឆ្នាំៗ ។ ថ្មីៗនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានរកឃើញថា មានបណ្តាញជនឧក្រិដ្ឋពួនសម្ងំប្រព្រឹត្តបទល្មើសនៅកម្ពុជា និងបង្កឲ្យមានជនរងគ្រោះ ទាំងជនជាតិខ្មែរ និងជនបរទេស ។

រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់បើកប្រតិបត្តិការដើម្បីស៊ើបអង្កេត បង្ក្រាបបទល្មើសដែលកើតមានក្នុងព្រះរាជាណាចក្រកម្ពុជា ។ គិតចាប់ពីខែសីហា ឆ្នាំ២០២២ មកដល់ខែវិច្ឆិកា ឆ្នាំ២០២៣នេះ សមត្ថកិច្ចបានទទួលបណ្តឹង ឬសេចក្តីរាយការណ៍តាមរយៈ Facebook page **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ក្នុងរាជរដ្ឋាភិបាលនីតិកាលទី៦ ក៏ដូចជា តាមប្រព័ន្ធផ្លូវការរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចំនួន១.២៧៦សំណើ ។ ក្នុងនោះ ក្រុមប្រតិបត្តិការ បានធ្វើអន្តរាគមន៍ ស្រាវជ្រាវរុករកបទល្មើសបានរហូតដល់១២១៣ករណី គឺប្រមាណ ៩៧.៧០% បានរកឃើញមនុស្ស ២.១៥៥នាក់ ស្រី២៦៩នាក់ លើ២១សញ្ជាតិ ។ យោងតាមលទ្ធផលជាក់ស្តែង ដែលត្រូវបានរកឃើញក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងអាចបញ្ជាក់ជា ភស្តុតាងជាក់ស្តែង ថាមិនមានជនរងគ្រោះ ដែលកំពុងជាប់ក្នុងការបង្ខាំង ឬបង្ខំធ្វើការខុសច្បាប់តាមប្រព័ន្ធល្បែងឆបោក រហូតដល់ទៅ ១០០.០០០នាក់ ដូចការផ្សព្វផ្សាយចោទប្រកាន់ឡើយ ។ ដោយឡែកជនរងគ្រោះ និងជនងាយរងគ្រោះ ដែលត្រូវបានបញ្ជូនមកពីបរទេសក្តី ឬដែលត្រូវបានរកឃើញក្នុងប្រទេសក្តី ជាជនជាតិខ្មែរក្តី ជាជនបរទេសក្តី គឺត្រូវបានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូដែលមានមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ ផ្តល់សេវាដើម្បីគាំពារជនរងគ្រោះ និងធ្វើសមាហរណកម្ម ជាបន្តបន្ទាប់ ។

ទាំងអស់នេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ និងមានរចនាសម្ព័ន្ធ ប្រទាក់ក្រឡា តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងមានកិច្ចសហការទូលំទូលាយ រហូតដល់ ថ្នាក់តំបន់ និងពិភពលោក ក្នុងគោលដៅ បង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងដាច់ខាត អំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មបែបទាសភាព និងបានបំផ្លាញដល់កិត្តិយស សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ និងរហូតដល់អាយុជីវិតជនរងគ្រោះ យ៉ាងអមនុស្សធម៌ ។ ទោះបីជា អំពើជួញដូរមនុស្ស មិនទាន់ផុតរលត់ក្តី ក៏បេសកកម្មនេះ មិនទាន់ត្រូវបានបញ្ចប់ដែរ ហើយនឹងបន្តខិតខំបន្ថែមទៀតកាន់តែខ្លាំង ដែលទាមទារឲ្យមានការគាំទ្រ និងកិច្ចសហការកាន់តែទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ឲ្យបានជោគជ័យ ។

**លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ មានប្រសាសន៍ប្រគេន និងគោរពជម្រាបជូនថា ក្នុងនាមអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំព្រះករុណា នាងខ្ញុំម្ចាស់ សូមគោរពថ្លែងនូវអំណរគុណសារជាថ្មី ចំពោះ ព្រះវត្តមាន និងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ** ទាំងអស់ ដែលបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់ ក្នុងការចូលរួមក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា និងសូមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធិក្នុងលោក សូមប្រទាននូវស័ព្ទសាធុការពរ ថ្វាយ ប្រគេន និងជូន ដល់ សម្តេចព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមប្រកបដោយ ពុទ្ធពរទាំងបួន ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

## III. បទយកការណ៍ កិច្ចសម្ភាសន៍ ចម្រៀង និងរបាំប្រពៃណី

- ការចាក់បញ្ចាំងខ្សែវីដេអូបទយកការណ៍ ស្តីពីស្ថានភាព នៃការជួញដូរមនុស្ស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា
- កិច្ចសម្ភាសន៍ជាមួយ **លោក ប៊ិត សំរេច** អំពីខ្សែជីវិតរយៈពេល១៤ឆ្នាំ ត្រូវបានមេខ្យល់លក់បន្តទៅធ្វើជាទាសករលើទូកនេសាទនៅក្នុងប្រទេសថៃ
- ការស្តាប់ និងទស្សនាកំសាន្តនូវបទចម្រៀងមានចំណងជើងថា **ជីវិតទាសករនេសាទ** ច្រៀងដោយ **លោក ប៊ិត សំរេច**
- ការស្តាប់ និងទស្សនាកំសាន្តនូវបទចម្រៀង និងសាច់រឿង ស្តីពីការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងគ្មានឯកសារត្រឹមត្រូវ មានចំណងជើងថា **កុំប្រថុយអី**
- ការទស្សនាវីដេអូចែករំលែកបទពិសោធន៍ជីវិត ដែលបានចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ពេលគាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ និងបានកសាងជីវិតជាថ្មី
- ទស្សនាការសម្តែងសិល្បៈរបាំប្រពៃណីខ្មែរ ដែលមានចំណងជើងថា មរតកតន្ត្រីខ្មែរ សម្តែងដោយ ក្រុមសិល្បៈករ សិល្បៈការិនី នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## IV. ប្រសាសន៍សំណេះសំណាល និងអនុសាសន៍ដឹកនាំ

**ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយឯកឧត្តម អភិសន្តិបណ្ឌិត មានប្រសាសន៍ថា ថ្ងៃនេះ ក្នុងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំផ្ទាល់ និងភរិយា មានសេចក្តីរំភើប និងសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួមជាអធិបតី ក្នុងឱកាសប្រារព្ធទិវាជាតិ ១២ធ្នូ ប្រឆាំងការជួញដូរមនុស្ស ដ៏មហានក្ខត្តឫក្ស នាពេលនេះ ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានតម្កល់នូវការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការការពារឲ្យបាននូវសន្តិភាពជាតិ សន្តិសុខសង្គម ស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ដោយពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ កាន់តែទូលំទូលាយ និងការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយថាមពល និងសក្តានុពល ។ រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តការប្តេជ្ញាចិត្តយ៉ាងមុះមុត ប្រឆាំងដាច់ខាតនូវអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសឧក្រិដ្ឋដទៃទៀត ដែលបាន និងកំពុងតែយាយី បំផ្លាញដល់សង្គមជាតិ យ៉ាងធ្ងន់ធ្ងរ ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ រហូតដល់អាយុជីវិតប្រជាពលរដ្ឋ ក៏ដូចជាបានបំផ្លាញដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងសេដ្ឋកិច្ចជាតិយ៉ាងធ្ងន់ធ្ងរ ។

ក្នុងអំឡុងពេលជាងពីរទសវត្សរ៍កន្លងមកនេះ បទល្មើសជួញដូរមនុស្សក្នុងតំបន់ និងនៅតាមបណ្តាប្រទេសលើពិភពលោក មិនបានថមថយឡើយ បើទោះបីជាមានការខិតខំប្រឹងប្រែងពីបណ្តារដ្ឋាភិបាលនៃប្រទេសតូចធំទាំងឡាយយ៉ាងណាក៏ដោយ ។ ប្រទេសនីមួយៗ ខិតខំបង្កើតឲ្យមានច្បាប់ គោលនយោបាយ យន្តការជាតិ យុទ្ធសាស្ត្រ វិធានការ និងវិធីសាស្ត្រជំនាញដ៏សម្បូរបែប ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស តែនៅតែមានជនរងគ្រោះកាន់តែច្រើនឡើង ដែលបាននិងកំពុងរងទុក្ខវេទនាដោយការធ្វើទុក្ខបុកម្នេញ និងកេងប្រវ័ញ្ចពីឧក្រិដ្ឋជន ។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់ឆ្លងកាត់ឧបសគ្គ និងដោះស្រាយជាបណ្ដើរៗ តាំងពីដំណាក់កាលប្រទេសមានសង្គ្រាមស៊ីវិល ជំងឺរាតត្បាត គ្រោះធម្មជាតិ និងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ។ ដៃម្ខាង ពង្រឹងប្រព័ន្ធគ្រប់គ្រង តាមរយៈកំណែទម្រង់យ៉ាងស៊ីជម្រៅ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ដៃម្ខាងត្រូវបង្កើនសមត្ថភាពក្នុងការរក្សាឲ្យបាននូវស្ថេរភាពនៃកំណើន ម៉ាក្រូសេដ្ឋកិច្ច ការពារសន្តិសុខជាតិ និងសុវត្ថិភាពសង្គម នៅគ្រប់ច្រកល្ហក និងគ្រប់ស្ថានភាព នៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាលយើង បានយកចិត្តទុកដាក់ដោះស្រាយជីវភាពតាមរយៈការបង្កើតការងារ មុខរបរខ្នាតតូច និងមធ្យម ការបង្កើនផលិតភាពកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ជាដើម ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានជួយគាំទ្រ ផ្គត់ផ្គង់ដល់ជនទុរគត ឬគ្រួសារក្រីក្រលំបាក និងងាយរងគ្រោះអំឡុងកូវីដ១៩ ដែល រាជរដ្ឋាភិបាលបានចំណាយទឹកប្រាក់រាប់ពាន់លានដុល្លា ក្នុងមួយឆ្នាំៗ ដើម្បីជួយទ្រទ្រង់ និងស្ដារជីវភាព បងប្អូនប្រជាពលរដ្ឋ ដែលជួបការលំបាក និងរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងសង្គម បានយ៉ាងល្អប្រសើរ និងដើម្បីបង្ការទប់ស្កាត់ និងកាត់បន្ថយភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ដែលធ្វើការសម្រេចចិត្តដោយប្រថុយប្រថាន ធ្វើតាមការអូសទាញរបស់ជនខិលខូច ដែលព្យាយាមឆក់ឱកាសកេងចំណេញ ពីស្ថានភាពដ៏លំបាករបស់ប្រជាពលរដ្ឋ ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងឲ្យតម្លៃខ្ពស់ ទៅលើភាពរីកចម្រើន នៃបច្ចេកវិទ្យា និងព្យាយាមពង្រីកចំណេះដឹងដល់មន្ត្រីរាជការ កងកម្លាំងគ្រប់ប្រភេទ ព្រមទាំងប្រជាពលរដ្ឋ ឲ្យចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីទំនាក់ទំនងគ្នា បានកាន់តែឆាប់រហ័ស ធ្វើជាមធ្យោបាយសម្រាប់ការសិក្សាស្រាវជ្រាវ អភិវឌ្ឍចំណេះដឹង និងជំនាញ គ្រប់គ្រងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្មខ្នាតតូច មធ្យម ឬធំ រហូតដល់ បានពង្រីកវិសាលភាព នៃការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មានក្នុងប្រព័ន្ធការងារឲ្យក្លាយជារដ្ឋបាលបែបឌីជីថល ។ ជាការពិតណាស់ វិទ្យាសាស្ត្រដ៏ទំនើប ជឿនលឿនទាំងឡាយ ត្រូវបានបង្កើតឡើងដើម្បីបម្រើក្ដីសុខក្សេមក្សាន្ត និងការអភិវឌ្ឍរីកចម្រើនរបស់មនុស្សជាតិ ។ ទោះបីជាយ៉ាងនេះក្ដី បច្ចេកវិទ្យា ក៏ត្រូវបានឧក្រិដ្ឋជនប្រើប្រាស់ធ្វើជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការអូសទាញមនុស្សឲ្យធ្លាក់ចូលអន្ទាក់នៃបទឧក្រិដ្ឋគ្រប់រូបភាព រួមទាំងការជួញដូរមនុស្ស និងកេងប្រវ័ញ្ចគ្រប់ទំរង់ ផងដែរ ។ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំរកគ្រប់មធ្យោបាយ ធនធាន និងបច្ចេកទេស ធ្វើការស៊ើបអង្កេតរុករកបណ្ដាញជនល្មើស យ៉ាងសកម្ម និងបានបំផ្លាញប្រសិទ្ធភាពបទល្មើសរបស់ជនទុច្ចរិត និងសង្គ្រោះជនទាំងឡាយដែលរងគ្រោះ និងងាយរងគ្រោះ បានជាបន្តបន្ទាប់ ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍ ថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនៃបណ្ដាប្រទេសជាមិត្ត ដែលតែងតែបានរួមសហការ ក្នុងការដោះស្រាយបញ្ហារួមគ្នាប្រកបដោយការទទួលខុសត្រូវ ។ យើងត្រូវការកិច្ចសហប្រតិបត្តិការដ៏ល្អ ដើម្បីការពារប្រជាជនយើង និងតំបន់យើង ឲ្យមានសន្តិសុខល្អប្រសើរ ។

ក្នុងតួនាទីជា ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **ឯកឧត្តមអភិសន្តិបណ្ឌិត** បានប្រកាសក្នុងវេទិកានេះនូវការប្ដេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងចាត់ទុកថា «**ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧**» ដើម្បីការលើកកម្ពស់សន្តិសុខ សុវត្ថិភាពមនុស្សជាតិ និងការលើកកម្ពស់សក្ដានុពល នៃធនធានមនុស្ស សម្រាប់ការអភិវឌ្ឍជាតិគ្រប់វិស័យ ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** បានមានប្រសាសន៍ថា ក្នុងនាម **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមជា ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមអំពាវនាវដល់ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាល រាជធានី ខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ លោក លោកស្រីជាប្រធានមន្ទីរ អង្គភាព ស្ថាប័ន ក្រោមឱវាទ គ្រប់ថ្នាក់ ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រហូតដល់កងកម្លាំងឈរជើងតាមបណ្តោយខ្សែបន្ទាត់ព្រំដែន សូមពង្រឹងស្មារតីទទួលខុសត្រូវក្នុងតួនាទី និងភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូនឲ្យបានម៉ត់ចត់ ពង្រឹងការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ ឲ្យមានការ ប្រុងប្រយ័ត្ន កុំជឿតាមការអូសទាញរបស់មេខ្យល់ជួញដូរមនុស្ស លើកកម្ពស់ការផ្តល់សេវាសាធារណៈឲ្យបានល្អ ពង្រឹងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ បង្កើនការផ្តល់កិច្ចគាំពារ និងការផ្តល់សេវាសមស្រប ជូនជនរងគ្រោះឲ្យបានត្រឹមត្រូវ កែលម្អ ការផ្តល់ឯកសារតាមផ្លូវច្បាប់ជូនពលករ ដែលមានបំណងធ្វើទេសន្តប្រវេសន៍ការងារនៅក្រៅប្រទេសឲ្យបានត្រឹមត្រូវទៅតាមគោលការណ៍កំណត់ **កាត់បន្ថយ ឈានទៅលុបបំបាត់ ការយកកម្រៃសេវា ក្រៅផ្លូវការ** ដែលនាំឲ្យមានភាពមិនប្រក្រតី និងបង្កើតអំពើពុករលួយក្នុងប្រព័ន្ធការងារ និងប៉ះពាល់ផលប្រយោជន៍របស់ពលករ ។ រាជរដ្ឋាភិបាល នីតិកាលទី៧ នឹងបង្កើនការយកចិត្តទុកដាក់ក្នុងការកែលម្អប្រព័ន្ធការងារ ឲ្យមានភាពស្អាតស្អំ តម្លាភាព និងគណនេយ្យភាព ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងបង្កើនផលប្រយោជន៍ជូនប្រជាពលរដ្ឋ ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍បញ្ជាក់ដោយ សង្ឃឹម និងជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាស្ថានតំណាង នៃបណ្តាប្រទេស ពាក់ព័ន្ធទាំងឡាយ ក៏ដូចជាអង្គការដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលដែលបាន និងកំពុងធ្វើការងារក្នុងគោលដៅប្រឆាំងអំពើជួញដូរមនុស្ស នឹងនៅតែបន្តកិច្ចសហការឲ្យបានកាន់តែទូលំទូលាយ ដើម្បីបង្កើនប្រសិទ្ធភាព នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការពារសិទ្ធិ ផលប្រយោជន៍របស់ប្រជាពលរដ្ឋនៃបណ្តាប្រទេសដែលត្រូវបានឧក្រិដ្ឋជនជួញដូរ និងកេងប្រវ័ញ្ចតាមគ្រប់រូបភាព ។

ជាទីបញ្ចប់នេះ **ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍ បួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ បារមីវត្ថុសក្តិសិទ្ធិ ទាំងឡាយក្នុងលោក សូមប្រទាននូវសព្ទសាធុការពរបវរមហាប្រសើរថ្វាយ ប្រគេនព្រះរាជាគណៈមន្ត្រីសង្ឃ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមបានប្រកបដោយបុណ្យបារមី និងសូមជួយរក្សាការពារ ឯកឧត្តម លោកជំទាវ លោក លោកស្រី កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ព្រមទាំងក្មួយៗយុវជនយុវនារី សូមបានជួបប្រទះតែពុទ្ធពរទាំងឡាយបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

## IV. ពិធីប្រគល់លិខិតថ្លែងអំណរគុណ

ដោយមើលឃើញអំពីកិច្ចខិតខំប្រឹងប្រែង និងការចូលរួមសហការ គាំទ្រ យកអស់ពីកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី ធនធាន របស់អង្គការដៃគូជាតិ អន្តរជាតិមួយចំនួនជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការប្រឆាំង ទប់ស្កាត់ និងបង្ក្រាប រាល់បទល្មើសជួញដូរមនុស្សនៅកម្ពុជានាពេលកន្លងមក និងជាការលើកទឹកចិត្ត ក៏ដូចជាការតបស្នងចំពោះកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង **លោកជំទាវ** បានប្រគល់លិខិតថ្លែងអំណរគុណ ជូនដល់អង្គការដៃគូជាតិ អន្តរជាតិមួយចំនួន ដូចជា៖ អង្គការ IOM, ERIKS, CHAB DAI,

CARITAS CAMBODIA, PLAN International, APLE, A21, AIM, ARM Cambodia, RATANAK International, APLE, HAGAR, CPU, Child fund, **លោកស្រី ជូ ប៊ុនលាន** និង **លោកស្រី ប៉ុក បញ្ញាវិចិត្រ** ។

ការប្រារព្ធទិវាជាតិ ១២ធ្នូ ដើម្បីប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង **លោកជំទាវ** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបញ្ចប់នៅវេលាម៉ោង ១៦:៣០ នាទីល្ងាច ថ្ងៃខែឆ្នាំដដែល ក្នុងបរិយាកាសសប្បាយរីករាយ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក សោ ស៊ីនួន

**គោរពជូន**

**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ**

មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ៦រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០២៣

**ប្រធានក្រុមការងារកំណត់ហេតុ និងរបាយការណ៍**

ឧត្តមសេនីយ៍ទោ. អ៊ុំ ភារមិន្ទ

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ៧រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់

ជូ_ប៊ុនអេង